**វេទិកាពិភាក្សាស្តីពី "ផែនទីវិថីអាស៊ាន៖ តើក្រុមហ៊ុនត្រូវរៀបចំយុទ្ធសាស្ត្រថ្មីៗ យ៉ាងដូចម្តេច នៅក្នុងតំបន់អាស៊ីអាគ្នេយ៍"**

កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៥ លោកជំទាវ ជា សិរី អគ្គនាយកបច្ចេកទេសនៃធនាគារជាតិនៃកម្ពុជា បានអញ្ជើញជាកិត្តិយសចូលរួមក្នុងវេទិកាពិភាក្សាអន្តរជាតិរបស់ធនាគារ CIMB ស្តីពី "ផែនទីវិថីអាស៊ាន ៖ តើក្រុមហ៊ុនត្រូវរៀបចំយុទ្ធសាស្ត្រថ្មីៗ យ៉ាងដូចម្តេច នៅក្នុងតំបន់អាស៊ីអាគ្នេយ៍" នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ។

វេទិកានេះរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយពីរបាយកាណ៍របស់សេដ្ឋវិទូនៃធនាគារ CIMB និងការបង្កើតបណ្តុំព័ត៌មានស្តីពី "ការយល់ដឹងអំពីអាស៊ាន" លើគេហទំព័រ ។ របាយការណ៍និងព័ត៌មានទាំងនេះ បង្ហាញពីលទ្ធផលនៃការស្ទង់មតិលើវិធីសាស្ត្រដែលក្រុមហ៊ុនត្រៀមខ្លួនសម្រាប់ការធ្វើសមាហរណកម្ម និងសេរីភាវូបនីយកម្មសេដ្ឋកិច្ចនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងទស្សនៈរបស់វាគ្មិននិងភ្ញៀវកិត្តិយសទាក់ទងនឹងសហគមន៍សេដ្ឋកិច្ចអាស៊ាន ។




លំដាប់ពីឆ្វេងទៅស្តាំ៖

១/- លោក Justin Wood ប្រធានអង្គភាពសេដ្ឋវិទូអាស៊ីអាគ្នេយ៍

២/- លោកជំទាវ ជា សិរី អគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា

៣/- លោកស្រី Rebecca Sta Maria អគ្គលេខាធិការ ក្រសួងឧស្សាហាកម្មនិងពាណិជ្ជកម្មអន្តរជាតិ

៤/- លោក Sajith Sivanandan ប្រធាននាយកប្រតិបត្តិ ក្រុមហ៊ុន Google ប្រទេសម៉ាឡេស៊ី និង

៥/- លោក Tan Sri Munir Majid វិទ្យាស្ថានស្រាវជ្រាវអាស៊ាន CIMB